# គណបក្ស ភ្លើងទៀន

# CANDLELIGHT PARTY

**សីលធម៌ សច្ចធម៌ យុត្តិធម៌**

# សេចក្តីថ្លែងការណ៍

**គណបក្ស ភ្លើងទៀន** សម្តែងការសោកស្តាយចំពោះក្រុមប្រឹក្សាធម្មនុញ្ញ ដែលបានបដិសេធបណ្តឹងតវ៉ាការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ របស់គណបក្ស ភ្លើងទៀន ដែលមាន ២៥ (ម្ភៃប្រាំ) មណ្ឌលរាជធានី ខេត្ត។

គួររំលឹកថា **គណបក្ស ភ្លើងទៀន** បានបំពេញពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ របស់គណបក្ស ភ្លើងទៀន ដោយភ្ជាប់ឯកសារគ្រប់គ្រាន់តាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ហើយបានដាក់ជូន គ.ជ.ប តាមពេលវេលាកំណត់ត្រឹមត្រូវ។ ប៉ុន្តែ គ.ជ.ប នៅតែសម្រេចបដិសេធការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ របស់គណបក្ស ភ្លើងទៀន ដោយសំអាងថា គណបក្ស ភ្លើងទៀន មិនបានជូនភ្ជាប់នូវប្រកាស ស្តីពីការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ដែលមានបញ្ជាក់នីត្យានុកូលកម្ម។ ការសម្រេចបែបនេះ គឺជាការរំលោភមាត្រា២៧ កថាខណ្ឌទី២ ចំណុចទី១ និងមាត្រា៣២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ព្រមទាំងមាត្រា៤២ ចំណុចទី៤ ចំណុចទី១៣ ចំណុចទី២៤ និងចំណុចទី២៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងរំលោភប្រការ៤.៧ ចំណុច៤.៧.៣.១ នៃបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៧ ដែល គ.ជ.ប ខ្លួនឯងបានអនុម័ត និងដាក់ឱ្យប្រើកាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២។

**គណបក្ស ភ្លើងទៀន** បានបន្តនីតិវិធីស្របតាមច្បាប់ ដាក់ពាក្យបណ្តឹងតវ៉ាចំពោះសេចក្តីសម្រេចបដិសេធរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មកក្រុមប្រឹក្សាធម្មនុញ្ញ ដោយបង្ហាញជូនឯកសារគ្រប់គ្រាន់បញ្ជាក់អំពីភាពស្របច្បាប់របស់គណបក្ស ភ្លើងទៀន ដែលបានចុះបញ្ជីគណបក្សនយោបាយ នៅក្រសួងមហាផ្ទៃ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ ដើម្បីទទួលបានសិទ្ធិចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ប៉ុន្តែត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញ សម្រេចបដិសេធ នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣នេះ។

**គណបក្ស ភ្លើងទៀន** យល់ឃើញថា សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលបដិសេធការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ របស់គណបក្ស ភ្លើងទៀន គឺ៖

ផ្ទះលេខ ៣២០ ផ្លូវលេខ ១០ម៉ែត្រថ្មី បុរីពិភពថ្មី ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
#320, Street 10m Thmey, Borey Piphob Thmey, Bayarb Village, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh
Website: www.candlelightparty.org / Email: info@candlelightparty.org

១-មិនស្របតាមស្មារតីនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ២៣ តុលា ១៩៩១, រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ច្បាប់ជាធរមាននានា ជាពិសេស ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីគណបក្សនយោបាយ។

២-ប៉ះពាល់ដល់សិទ្ធិក្នុងការចូលរួមការបោះឆ្នោតរបស់គណបក្ស ភ្លើងទៀន ដែលជាគណបក្សនយោបាយបានចុះបញ្ជីត្រឹមត្រូវ តាមលក្ខខណ្ឌដូចមានចែងក្នុងច្បាប់ស្តីពីគណបក្សនយោបាយ និងត្រូវបានទទួលស្គាល់ដោយក្រសួងមហាផ្ទៃ ព្រមទាំងត្រូវបាន គ.ជ.ប ទទួលស្គាល់ការចុះបញ្ជីគណបក្សនយោបាយក្នុងការចូលរួមការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៥ ឆ្នាំ២០២២ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ លើកទី១ ដែលទើបបង្កើត និងបំបែក កាលពីថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២៣។

៣-ប៉ះពាល់ដល់សិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោត របស់ប្រជាពលរដ្ឋ ដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

៤-ប៉ះពាល់ដល់សិទ្ធិ និងការសម្រេចចិត្ត ក្នុងការចូលរួមការបោះឆ្នោតជ្រើសរើសតំណាង ស្របតាមឆន្ទៈរបស់ប្រជាពលរដ្ឋ ជាពិសេសប្រជាពលរដ្ឋខ្មែរប្រមាណជិត ២លាននាក់ ដែលបានបោះឆ្នោតគាំទ្រគណបក្ស ភ្លើងទៀន នៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០២២ កន្លងមកថ្មីៗនេះ។

**គណបក្ស ភ្លើងទៀន** សូមការយោគយល់ និងអធ្យាស្រ័យ ពីសំណាក់សមាជិក សមាជិកា សកម្មជន និងថ្នាក់ដឹកនាំគណបក្សគ្រប់លំដាប់ថ្នាក់ ព្រមទាំងបងប្អូនប្រជាពលរដ្ឋខ្មែរទាំងអស់ ដែលគណបក្ស ភ្លើងទៀន មិនអាចចូលរួមក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ នេះបាន ហើយសង្ឃឹមថា សមាជិក សមាជិកា និងសកម្មជនគណបក្ស ព្រមទាំងបងប្អូនប្រជាពលរដ្ឋខ្មែរទាំងអស់ដែលស្រលាញ់យុត្តិធម៌ សេរីភាព និងលទ្ធិប្រជាធិបតេយ្យ នៅតែមានឆន្ទៈរឹងមាំ បន្តគាំទ្រគណបក្ស ភ្លើងទៀន តទៅទៀត។

**គណបក្ស ភ្លើងទៀន** នៅតែមានឆន្ទៈក្នុងការចូលរួមការបោះឆ្នោត ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីចូលរួមជម្រុញ និងលើកស្ទួយគ្រឹះនៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងការអភិវឌ្ឍប្រទេសជាតិ៕

**ថ្ងៃព្រហស្បតិ៍ ០៦កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧**

**រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣**

**គណបក្ស ភ្លើងទៀន**

ព័ត៌មានបន្ថែមសូមទាក់ទង:

- ០៧៨ ៤៤ ៦៥ ៨៨